# ការស្ទង់មតិអំពីសមធម៌ផ្នែកសុខភាពសហគមន៍ឆ្នាំ ២០២៣

## ទំព័រយល់ព្រម

គោលបំណងនៃការស្ទង់មតិសមធម៌សុខភាពសហគមន៍នេះ គឺជួយឱ្យសហគមន៍កែលម្អស្ថានភាពនានាដែលជះឥទ្ធិពលទៅលើសុខភាព។ ដើម្បីកែលម្អសុខភាពបុគ្គលគ្រប់រូបនៅក្នុងរដ្ឋម៉ាសាឈូសិត យើងចាំបាច់ត្រូវស្តាប់បុគ្គលដែលធ្លាប់ត្រូវបានគេបដិសេធពីមុនមកចំពោះឱកាសស្មើភាពគ្នាខាងផ្នែកសុខភាព។

ការស្ទង់មតិនេះត្រូវបានបង្កើតឡើងដោយសហការជាមួយប្រជាពលរដ្ឋ និងអង្គការសហគមន៍នៅទូទាំងរដ្ឋ។ តាមរយៈការស្ទង់មតិនេះ ការយល់ឃើញនិងបទពិសោធន៍របស់អ្នកគឺជាផ្នែកមួយនៃកិច្ចដំណើរការធ្វើសេចក្តីសម្រេច។ ក្រសួងសុខភាពសាធារណៈ នឹងប្រើប្រាស់ព័ត៌មានដែលបានប្រមូលនៅក្នុងការស្ទង់មតិនេះដើម្បីធ្វើឱ្យប្រាកដថា កម្មវិធីលើកម្ពស់សុខភាពកំពុងបំពេញតាមតម្រូវការរបស់មនុស្សគ្រប់រូបនៅក្នុងរដ្ឋម៉ាសាឈូសេត។ បន្ទាប់មកនៅក្នុងឆ្នាំនេះ អ្នកអាចចូលទៅកាន់គេហទំព័ររបស់យើង https://www.mass.gov/chei ដើម្បីស្វែងរកលទ្ធផល និងស្វែងយល់បន្ថែមអំពីបទពិសោធន៍សហគមន៍របស់អ្នក។

សហគមន៍អាចប្រើប្រាស់លទ្ធផលស្ទង់មតិនេះដើម្បីធ្វើការផ្លាស់ប្តូរដែលផ្តល់ឱ្យបុគ្គលគ្រប់រូបនូវឱកាសសម្រាប់សុខភាពកាន់តែល្អប្រសើរ ដូចជាការស្នើសុំនិងការចំណាយប្រាក់ដើម្បីដោះស្រាយបញ្ហាតម្រូវការសហគមន៍ ការកែលម្អទំនាក់ទំនងជាមួយប្រជាពលរដ្ឋ និងការបង្កើតគោលនយោបាយនានាដែលគាំទ្រដល់មនុស្សដែលជួបប្រទះឧបសគ្គមិនយុត្តិធម៌ចំពោះបញ្ហាសុខភាព។ រឿងរ៉ាវរបស់អ្នកអាចកំណត់អនាគតរបស់យើងបាន។

**តើនរណាអាចធ្វើការស្ទង់មតិនេះបាន?** អ្នកអាចធ្វើ ការស្ទង់មតិនេះបាន ប្រសិនបើអ្នក៖

- មានអាយុចាប់ពី 14 ឆ្នាំឡើងទៅ

  និង

- រស់នៅក្នុងរដ្ឋម៉ាសាឈូសិតខ្លះៗ ឬពេញមួយឆ្នាំ

**អំពីការស្ទង់មតិ៖**

**ចម្លើយរបស់អ្នកគឺមានលក្ខណៈជាអនាមិក និងមិនអាចតាមដានដឹងពីអ្នកបានឡើយ។** ជាធម្មតា ការស្ទង់មតិនេះនឹងចំណាយពេលប្រហែល 20 នាទីដើម្បីបំពេញ។

ការស្ទង់មតិនេះនឹងសួរសំណួរអំពី៖

- លទ្ធភាពទទួលបានតម្រូវការមូលដ្ឋានរបស់អ្នក ដូចជាការថែទាំសុខភាពនិងមធ្យោបាយធ្វើដំណើរ
- សុខភាពផ្លូវកាយនិងផ្លូវចិត្ត និងសុខុមាលភាព
- បទពិសោធន៍របស់អ្នកជាមួយនឹងជំងឺ COVID-19 រួមទាំងរោគសញ្ញាជាបន្តផងដែរ
- បទពិសោធន៍របស់អ្នកជាមួយនឹងលំនៅដ្ឋាន ការអប់រំ និងការងារ
- ព័ត៌មានមូលដ្ឋានអំពីអ្នក ដូចជាអាយុ ភេទ ពូជសាសន៍ និងកន្លែងដែលអ្នករស់នៅ (**យើងមិនសាកសួរព័ត៌មានដែលអាចយកទៅប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណរបស់អ្នកបាននោះទេ)**

**នៅខាងចុងបញ្ចប់ការស្ទង់មតិគឺជាតំណភ្ជាប់ទៅកាន់ធនធាន** ដើម្បីជួយភ្ជាប់អ្នកទៅកាន់ចំណុចមួយចំនួនដូចជាជំនួយស្បៀងអាហារនិងសេដ្ឋកិច្ច សេវាសុខភាពផ្លូវចិត្តនិងសេវាការសេពគ្រឿងញៀន

ការចូលរួមរបស់អ្នកនៅក្នុងការស្ទង់មតិនេះគឺជា**ការស្ម័គ្រចិត្តទាំងស្រុងតាមជម្រើស។ អ្នកអាចរំលងសំណួរណាមួយដែលអ្នកមិនចង់ឆ្លើយ។** អ្នកអាចបញ្ឈប់ធ្វើការស្ទង់មតិនេះបានគ្រប់ពេល និងគ្រប់ហេតុផលទាំងអស់។

**មានសំណួរតិចតួចដែលពាក់ព័ន្ធនឹងការចូលរួមធ្វើការស្ទង់មតិនេះ។** សំណួរមួយចំនួនអាចនឹងសួរអំពីប្រធានបទដែលអាចធ្វើឱ្យនឹកឃើញការចងចាំដ៏ឈឺចាប់ ភាពថប់បារម្ភ និងស្ត្រេស។ **អ្នកអាចផ្អាក ឬឈប់ធ្វើការស្ទង់មតិនេះបាន ប្រសិនបើអ្នកមានអារម្មណ៍មិនស្រួលក្នុងចិត្ត។** មិនមានអត្ថប្រយោជន៍ដោយផ្ទាល់សម្រាប់អ្នកតាមរយៈការស្ទង់មតិនោះទេ ប៉ុន្តែព័ត៌មានដែលអ្នកចែករំលែកប្រាប់ នឹងជួយឱ្យនាយកដ្ឋានសុខភាពសាធារណៈ (MA-DPH) យល់អំពីតម្រូវការដ៏ធំបំផុតរបស់អ្នករស់នៅរដ្ឋម៉ាសាឈូសេត ដើម្បីឱ្យនាយកដ្ឋានអាចផ្តល់ការគាំទ្រនៅពេលដែលគេត្រូវការវាបំផុត និងធ្វើការជាមួយសហគមន៍ដើម្បីទទួលបានសុខភាពល្អប្រសើរ។

**តើមានសំណួរដែរឬទេ?**

ប្រសិនបើអ្នកមានសំណួរណាមួយអំពីការស្ទង់មតិនេះ សូមផ្ញើអ៊ីមែលទៅកាន់ស្ថាប័នគំនិតផ្តួចផ្តើមសមធម៌សុខភាពសហគមន៍ (Community Health Equity Initiative) តាមរយៈ chei@mass.gov។

ការស្រាវជ្រាវនេះត្រូវបានឯកភាពដោយក្រុមប្រឹក្សាត្រួតពិនិត្យស្ថាប័ន (MA-DPH Institutional Review Board, MA-DPH IRB) ដើម្បីធ្វើឱ្យប្រាកដថាការស្រាវជ្រាវនេះបំពេញតាមស្តង់ដាក្រមសីលធម៌និងបទបញ្ញត្តិដែលតម្រូវឱ្យមានជាចាំបាច់ដើម្បីការពារអ្នកចូលរួម។ ប្រសិនបើអ្នកមានបំណងចង់ពិភាក្សាជាមួយបុគ្គលិកមកពីក្រុមប្រឹក្សា MA-DPH IRB អ្នកអាចទាក់ទងពួកគេតាមរយៈ DPH.IRB@mass.gov ឬតាមទូរស័ព្ទលេខ (617) 624-5647។

សូមអរគុណសម្រាប់ការចំណាយពេលនិងចំណាប់អារម្មណ៍របស់អ្នកក្នុងការស្ទង់មតិនេះ និងសម្រាប់ការចែករំលែកបទពិសោធន៍របស់អ្នកជាមួយយើង!